គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

លេខ ៤៩ ចេញផ្សាយថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
No. 49 Released on June 22, 2022

និយ័តករបរធនបាលកិច្ច
Trust Regulator

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# តួនាទី និងភារកិច្ចរបស់បុគ្គលិកជំនាញផ្នែកច្បាប់ក្នុងវិស័យបរធនបាលកិច្ច

## Roles and Responsibilities of Legal Specialist in Trust Sector




https://www.kindpng.com/imgv/hToomoo_commercial-law-clip-art-hd-png-download/

យោងតាមច្បាប់ស្តីពី “បរធនបាលកិច្ច” (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” បុគ្គលិកជំនាញផ្នែកច្បាប់នៅក្នុងវិស័យបរធនបាលកិច្ចមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

១. ផ្តល់ប្រឹក្សា និងត្រួតពិនិត្យឱ្យបានទៀងទាត់នូវអនុលោមភាពតាមច្បាប់ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន និងការអនុវត្តការងាររបស់នាយកប្រតិបត្តិ និងផ្នែកផ្សេងៗ។

២. រក្សាទុក និងត្រួតពិនិត្យឡើងវិញនូវនីតិវិធីអនុលោមភាពតាមច្បាប់ សម្រាប់ផ្នែកនីមួយៗរបស់ក្រុមហ៊ុនបរធនបាល។

៣. ត្រួតពិនិត្យ និង/ឬឃ្លាំមើលភាពមិនប្រក្រតីទាំងឡាយដែលកើតមាននៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុនបរធនបាល។ រាល់លទ្ធផល ដែលបានរកឃើញត្រូវរក្សាទុកជាឯកសារឱ្យបានត្រឹមត្រូវ។ ក្នុងករណីចាំបាច់ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវជូនដំណឹង និង/ឬប្រឹក្សាជាមួយបរធនបាលទាយក និង/ឬ **ន.ប.ធ.**។

៤. ទទួលបន្ទុករៀបចំគោលការណ៍តាមដានការអនុវត្តសកម្មភាពប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលធ្វើបច្ចុប្បន្នកម្ម និង/ឬផ្តល់ប្រឹក្សាដល់ក្រុមហ៊ុនបរធនបាល និង/ឬសកម្មភាពនៃក្រុមប្រឹក្សាភិបាលអំពីបញ្ហាអនុលោមភាពតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងការអភិវឌ្ឍបទប្បញ្ញត្តិ។

៥. ទទួលបន្ទុករៀបចំសៀវភៅមគ្គុទ្ទេសក៍អនុលោមតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់និយោជិតរបស់ក្រុមហ៊ុនបរធនបាល។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសៀវភៅមគ្គុទ្ទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។

៦. ត្រួតពិនិត្យ និងដោះស្រាយទំនាស់ផលប្រយោជន៍ផ្សេងៗ។

៧. រាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀតអំពីភាពមិនសមស្របនៃការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ចរបស់ក្រុមហ៊ុនបរធនបាល។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

៨. តួនាទី និងភារកិច្ចផ្សេងទៀត ដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on " Rules on the Management, Organization, and the Functioning of Trust ", the legal specialist has the following roles and responsibilities:

1. advise and regularly supervise compliance with laws related to the company's operations and the performance of the CEO and other divisions.

2. safeguard and supervise the compliance procedures for each division of the trustee company.

3. supervise and/or monitor any irregularities that occur in the operations of the trustee company. All results found must be properly archived. If necessary, the legal specialist shall inform and/or consult with the trustor/settlor or the Trust Regulator.

4. responsible for preparing policies to monitor the implementation of anti-money laundering, terrorism financing and financing of proliferation of weapons of mass destruction activities; laws against anti-money laundering, terrorism financing, and financing of proliferation of weapons of mass destruction and developing the provision.

5. responsible for preparing manuals in accordance with the law and ethics for employees of the trustee company. Legal specialist shall cooperate with relevant departments in reviewing and updating the handbook of compliance with the law and ethics.

6. supervise and resolve conflicts of interest.

7. report to the board and other relevant committees on the impropriety of managing and maintaining the trust of the trustee company.

8. Other roles and responsibilities in accordance with the laws and regulations.

**អត្ថបទ÷ កេត ស្រីនិច | Article: Ket Sreynich**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.